# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## អំពីកំហុសដោយខ្វះការពិចារណានិងទោសនៃសេចក្តីលោភមិនសម្រួលគ្នា ដោយលើកយករឿងក្នុងគតិលោកមកជាឧទាហរណ៍ផង

web site: hoksavann.org

ថ្ងៃទី២០ កុម្ភៈ ២០០៦

ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធសាសនា ក៏ដូចជាពាក្យប្រៀនប្រដៅរបស់ចាស់បូរាណខ្មែរបានរំឭកថា មុននឹងសំរេចចិត្តធ្វើអ្វីមួយ ក្នុងបញ្ហាគ្រួសារក៏ដូចជាបញ្ហាសង្គមប្រទេសជាតិ ត្រូវពិចារណាឲ្យបានល្អិតល្អន់ ឲ្យយល់ច្បាស់ជាមុនសិន ។ ទំរើខ្លះ ការពិចារណាអាចអនុវត្តខុសនាំខូចប្រយោជន៍ ហើយសោកសៅជាក្រោយ ។ ក្នុងន័យនេះ មានរឿងក្នុងគតិលោករបស់លោកសុត្តន្តប្រីជាឥន្ទ ទោះបីដាក់ចំណងជើងសៀវភៅថា គតិលោក ក៏មានទាក់ទងនិងគតិធម៌ដែរ ។ រឿងទាំងនោះ ទោះបីរឿងខ្លះមានសត្វធ្វើជាតួអង្គក៏ដោយ ក៏បានជាគតិប្រសើរណាស់ សំរាប់អប់រំសង្គមមនុស្ស ពិសេសសង្គមខ្មែរឲ្យឈ្លាសវៃក្នុងការរស់នៅ ព្រោះសត្វជាតួអង្គទាំងនោះជាតំណាងនៃមនុស្សនិងសង្គមមនុស្សហ្នឹងឯង ។ ដូចជារឿងអ្នកចំការពីរនាក់ប្តីប្រពន្ធ មានចិត្តសោកស្តាយដោយបានសម្លាប់សត្វស្កា ដោយយល់ខុសថា សត្វស្កានោះបានខាំសម្លាប់កូនរបស់ខ្លួន មកពីមានកំហឹងខ្វះការពិចារណា ។ ដំណើររឿងដោយសង្ខេបថា បុរសនិងនារីពីរនាក់ប្តីប្រពន្ធជាអ្នកចំការ បានចិញ្ចឹមសត្វស្កាមួយ ។ ថ្ងៃមួយ ពីរនាក់ប្តីប្រពន្ធបានចេញទៅធ្វើការខាងក្រៅ ទុកកូនខ្ចីនៅក្នុងអង្រឹងនិងសត្វស្កានោះឲ្យចាំផ្ទះ ។ ពេលដែលចេញផុតទៅ មានពស់មានពិសមួយ ដោយធុំក្លិនទឹកដោះក្នុងមាត់ទារក បានលួនចូលទៅក្នុងអង្រឹង ចឹកទារកនោះស្លាប់ទៅ ។ ពេលឮសូរទារកនោះយំ សត្វស្កាបានបោលយ៉ាងលឿនតម្រង់ទៅអង្រឹង ឃើញពស់ចឹកទារកនោះស្លាប់ ក៏ធ្វើការប្រយុទ្ធយ៉ាងអង់អាចជាមួយនឹងពស់ រហូតដល់ពស់នោះស្លាប់ទៅ ហើយខាំអូសទាញយកទៅទុកក្រោមជើងម៉ា ។ ពេលបុរសប្តីប្រពន្ធ

ត្រឡប់មកវិញ សត្វស្កាបានរត់ឆ្លេឆ្លាចុះឡើង ហាក់ដូចជាចង់ថ្លែងប្រាប់ម្ចាស់អំពីព្រឹត្តិការណ៍ពេលដែលខ្លួនចាំផ្ទះ ។ ម្ចាស់ផ្ទះប្ដីប្រពន្ធឃើញឈាមនៅនឹងមាត់ស្កា កើតមានសេចក្ដីសង្ស័យ ក៏រត់ទៅមើលកូនក្នុងអង្រឹង ឃើញកូនស្លាប់ដោយឃើញមានស្នាមជាំត្រង់ភ្លៅកូន ក៏សន្និដ្ឋានថា សត្វស្កាបានខាំកូនរបស់ខ្លួន ក៏កើតកំហឹងយកដំបងវាយសត្វស្ការហូតដល់ស្លាប់ទៅ ។ ងាកចុះងាកឡើង ស្រាប់តែឃើញពស់ដែលស្លាប់នៅក្រោមជើងម៉ា ក៏កើតសង្ស័យ ក៏ស្ទុះទៅពិនិត្យមើលស្នាមភ្លៅកូនដែលជាំម្ដងទៀត ទើបដឹងច្បាស់ថា ជាស្នាមពស់ចឹក ពុំមែនជាស្នាមស្កាខាំឡើយ ក៏កើតរន្ធត់ក្នុងចិត្ត យំអាណិតកូនផង សោកស្ដាយសត្វស្កា ដែលខ្លួនសម្លាប់ខ្វះការពិចារណាឲ្យបានម៉ត់ចត់ ដែលជាសត្វឥតទោស ជាសត្វមានគុណការពារកូនខ្លួនផង ។

រឿងនេះបានឲ្យមេរៀនថា អំពើគ្រប់យ៉ាងដែលគេធ្វើទាំងកំហឹង មិនបានពិចារណាផបានច្បាស់លាស់ជាមុន តែងមានការភ្លាត់ខុសខូចប្រយោជន៍ ហើយមានការសោកស្ដាយជាក្រោយ ។

រឿងនេះ បានជាមេរៀនថ្លៃថ្លាណាស់ សំរាប់ជនជាតិខ្មែរ ពិសេសអ្នកដឹកនាំខ្មែរក្នុងបច្ចុប្បន្ននិងទៅអនាគតទៀត មានការសម្លាប់គ្នាដោយខ្វះការពិចារណា តាំងពីក្រោយសម័យមហានគរ ម្ខាងទៅពឹងសៀម ម្ខាងទៀតទៅពឹងយួន ឲ្យជួយសម្លាប់ខ្មែរគ្នាឯង ក្នុងការដណ្ដើមអំណាចគ្នា ដែលធ្វើឲ្យរាជាណាចក្រខ្មែរ ដែលធ្លាប់តែធំទូលំទូលាយ និងមានអារ្យធម៌ខ្ពស់ ទៅជារួមតូចដូចសព្វថ្ងៃ ។ បច្ចុប្បន្ននេះ បើមិនប្រុងប្រយ័ត្នថែរក្សាទេ ទឹកដីខ្មែរនឹងត្រូវបាត់បង់ជាបន្តទៅទៀត ។ ជាមួយនឹងបញ្ហាទឹកដីនេះ បញ្ហាជនអន្តោប្រវេសន៍វៀតណាម ចូលមកប្រទេសកម្ពុជារាប់លាននាក់ដោយខុសច្បាប់ ក៏គ្មានការត្រួតពិនិត្យដោះស្រាយឡើយ ។ នេះជាគ្រោះថ្នាក់ធំណាស់របស់ប្រទេសកម្ពុជាទៅអនាគត ។

មានរឿងមួយទៀតនិទានថា មានសត្វភេពីរ ភេមួយរកស៊ីក្នុងទឹកជ្រៅ ភេមួយទៀតរកស៊ីក្នុងទឹករាក់ ។ ថ្ងៃមួយភេទាំងពីរចាប់បានត្រីរ៉ស់មួយ ចែកគ្នាឯងពុំដាច់ស្រេចក៏កើតជាជម្លោះ ហើយសំរេចនាំគ្នាទៅប្ដឹងសត្វចចក ឲ្យធ្វើជាចៅក្រមកាត់សេចក្ដីឲ្យខ្លួន ។ ឆ្កែចចកក៏កាត់សេចក្ដី ដោយកាត់ត្រីរ៉ស់នោះជាបីភាគ ខាងក្បាលឲ្យទៅភេដែលមុជទឹកជ្រៅ ខាងកន្ទុយទៅភេដែលមុជទឹករាក់ ចំណែកភាគកណ្ដាលចចកស៊ីខ្លួនឯង ។ ភេទាំងពីរនឹកតូចចិត្តណាស់ ដោយឃើញចចកស៊ីត្រង់ភាគកណ្ដាល ដែលសុទ្ធតែសាច់ ។ ឯភេដែលបានត្រង់កន្ទុយនឹកតូចចិត្តជាងគេ មិនដឹងធ្វើអ្វីនឹងចចកបាន បែរមកច្រណែនភេគ្នាឯងដែលបានត្រង់ក្បាល ។ កើតទុក្ខពុំសុខចិត្ត ភេទាំងពីរក៏នាំគ្នាទៅប្ដឹងខ្លាត្រី ខ្លាត្រីកាត់សេចក្ដីដោយយកជញ្ជីងត្រាជូមកថ្លឹង ក្បាលត្រីធ្ងន់ជាង ខ្លាត្រីខិនស៊ីសាច់អមក ដល់ថ្លឹងម្ដងទៀតខាងកន្ទុយធ្ងន់ជាង ខ្លាត្រីខិនស៊ីសាច់គល់កន្ទុយ ខ្លាត្រីក្លែងថ្លឹងមិនឲ្យស្មើ ស៊ីទៅស៊ីមកទាល់តែអស់សា

ច់រេចនៅសល់តែផ្សឹងទាំងសងខាង ទើបថ្លឹងក្រោយឲ្យស្មើគ្នា ហើយខ្លាត្រីថ្លែងទៅភេទាំងពីរថា ម្នានាំគ្នាយកទៅ យកណាមួយក៏បាន ខ្ញុំថ្លឹងឲ្យស្មើគ្នាហើយ គ្មានឃើញខ្វះទេ យុត្តិធម៌ហើយ ។ ភេតាំងពីរឃើញខ្លាត្រីក្លែងថ្លឹងស៊ីសាច់អស់ដូច្នេះ ក៏នឹកតូចចិត្តទ្វេលើងថែមទៀត នឹកស្តាយត្រីរ៉ស់ ដោយគិតខុសបែកសាមគ្គីគ្នា ចង់លោភយកតែឯង រហូតដល់ខានស៊ីទាំងអស់គ្នា ហើយក៏ដើរចេញរៀងៗខ្លួនទៅ ។ ពាក្យកាព្យថា ៖

ភេអើយភេពីរ ខេខឹងមមី បែកក្តីសាមគ្គា ព្រោះលោភតែឯង មិនបែងចែកគ្នា ទៅប្តឹងដល់វា ចចកឲ្យចែក ។ ធម្មជាតិចចក ជាសត្វលៃលក វាយយកចំណែក កណ្តាលសាច់ច្រើន ចំរើនអ្នកចែក ចុងដើមបំបែក បានភេទ្វេហា ។ ក្រោយមកភេខឹង ពាំត្រីទៅប្តឹង ខ្លាត្រីទៀតណា ខ្លាថ្លឹងត្រាជូ ស៊ីសាច់ផងណា ទំរាំស្មើគ្នា នៅសល់តែផ្សឹង ។

រឿងនេះ មានឧត្តមគតិពីរយ៉ាង គឺទីមួយ នៅក្រោមកាត់សេចក្តីអយុត្តិធម៌ស៊ីសំណូកពុករលួយ ដែលធ្វើកូនក្តីទាំងសងខាងខាតបង់ទាំងអស់គ្នា ឯប្រយោជន៍ទាំងអស់បានទៅលើចៅក្រម គឺឈ្លោះគ្នាបានចំណេញទៅលើចៅក្រម ។ ដូច្នេះរឿងនេះ ចៅក្រមខ្មែរក្តី អ្នកមានជម្លោះគ្នាក្តី គប្បីយករឿងនេះទៅពិចារណា ។ ទីពីរ ចំពោះបញ្ហាជាតិ ខ្មែរនិងខ្មែរទាស់គ្នា ដណ្តើមអំណាចគ្នា តាមប្រវត្តិសាស្ត្រ ម្ខាងទៅពឹងសៀម ម្ខាងទៀតទៅពឹងយួនដើម្បីឲ្យជួយច្បាំង បើម្ខាងណាមានជ័យជំនះត្រូវសងគុណគេ ទោះបីបាត់បង់ភោគទ្រព្យខ្មែរ បាត់បង់ទឹកដីខ្មែរក៏មិនហ៊ានតវ៉ា ព្រោះអំណាចរបស់ខ្លួនស្ថិតនៅលើគេការពារ ។៚

❑ ❑

❑